សាលាដំបូងខេត្តកណ្ដាល

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ៦១០ អក

ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២

**សាលក្រមព្រហ្មទណ្ឌ**

លេខ ១៣០ "ណ"

ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ ២០២២

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី ចៅក្រមប្រឹក្សា

លោក ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦១០ អ.ក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ដេវីត ហៅ វីត ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូ[redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នផ្ទះលេខ០១ ភូមិត្រពាំងគល់ សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស្រី (រស់) ម្ដាយឈ្មោះ [redacted] គីមស្រ៊ុន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។(ក្នុងឃុំ)

២. ឈ្មោះ [redacted] ចំណាត់ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូ[redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ខ្នា (រស់) ម្ដាយឈ្មោះ [redacted] ឌី (រស់)។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អំពើហិង្សា ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការត្រាច ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ឈ្មោះ [redacted] វាសនា ហៅស្ពា ឬ សីហា ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុនធឿន (រស់) ម្ដាយឈ្មោះ [redacted] សោភា (រស់) នៅលីវ ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល០៥ខែ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។(ក្នុងឃុំ)



Scanned with CamScanner

៤. ឈ្មោះ [redacted] សុវណ្ណរ៉ាវី ហៅវីហ្សុ ឬ ហុង ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សំអុល (ស្លាប់) ម្តាយឈ្មោះ [redacted] ផល់ឡឹង (រស់) នៅលីវ ជានីតិជនទោសពីមុនគ្មាន ។(ក្នុងឃុំ)

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដេវីត និងឈ្មោះ [redacted] វាសនា។

## ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖

កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៤ និង ០០នាទី ជនត្រូវចោទឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ជាអ្នកបើកបរម៉ូតូ និងជនត្រូវចោទឈ្មោះ [redacted] ដេវីត ហៅវីត ជាអ្នកជិះពីក្រោយ បានជិះម៉ូតូម៉ាកឃ្លិច ទៅធ្វើសកម្មភាពឆក់ទូរស័ព្ទដៃ នៅចំណុចផ្លូវបេតុងស្ថិតនៅក្នុងភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ពីក្នុងឃ្លុបម៉ូតូម៉ាកស្កុបពីរបស់ជនរងគ្រោះឈ្មោះ [redacted] អាលីហ្សា ដែលកំពុងធ្វើដំណើរតាមផ្លូវ រួចជនត្រូវចោទក៏បានបើកម៉ូតូ ដើម្បីរត់គេចខ្លួន លុះដល់ត្រង់ចំណុចព្រៃកតាហោ ជនត្រូវចោទឈ្មោះ [redacted] ដេវីត ហៅ វីត ក៏បានលោតចុះពីលើម៉ូតូ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបាន ចំណែកជនត្រូវចោទឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ក៏បានបើកម៉ូតូរត់គេចខ្លួនបាត់ ។ បន្ទាប់ពីសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ដេវីត ហៅ វីត ហើយជននេះបានសារភាពថាឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ជាមេក្លោងឱ្យជនត្រូវចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ឬ សីហា ឈ្មោះ [redacted] សុវណ្ណរ៉ាវី ហៅ វីហ្សុ ឬហុង ឈ្មោះ ឧត្តម និងឈ្មោះ សុះ ប្រព្រឹត្តសកម្មភាពឆក់ទូរស័ព្ទដៃ របស់ប្រជាពលរដ្ឋចំនួន០៨លើកមកហើយ ។ ទើបសមត្ថកិច្ចក៏បានបន្តធ្វើការស្រាវជ្រាវរហូតធ្វើការឃាត់ខ្លួណជនត្រូវចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ឬសីហា ឈ្មោះ [redacted] សុវណ្ណរ៉ាវី ហៅវីហ្សុ ឬ ហុង បន្ទាប់ពីកម្លាំងសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលក្រុងតាខ្មៅ បានធ្វើការឃាត់ខ្លួន ក៏បានធ្វើតេស្តទឹកនោម ជនត្រូវចោទជាលទ្ធផលវិជ្ជមាន សារធាតុញៀនក្នុងខ្លួន ។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៩៩ ដកសស ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៨៦៣ ដកសព ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៨៨៧ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ ៩៣០ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ដេវីត ឆ្លើយថា៖ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ប្រហែលពេលថ្ងៃត្រង់ ដោយពេលនោះខ្លួនបានជិះម៉ូតូ០២នាក់ ជាមួយឈ្មោះ [redacted] ចំណាត់ ដែលឈ្មោះ [redacted] ចំណាត់ ជាអ្នកឧបខ្លួន ហើយខ្លួនជិះម៉ូតូពីក្រោយ ។ ដោយពេលនោះខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះដោយពេលនោះជនរងគ្រោះទុកទូរស័ព្ទនៅក្នុងឃ្លុបម៉ូតូ ហើយម៉ូតូរបស់ខ្លួន និងម៉ូតូរបស់ជនរង



Scanned with CamScanner

គ្រោះ គឺជិះស្របទិសជាមួយគ្នា។ ដោយពេលនោះ ខ្លួនបានធ្វើសកម្មភាពលួចបានសម្រេច បាននូវទូរស័ព្ទIPHONE 7 ពណ៌ខ្មៅ០១គ្រឿង ខ្លួនទើបតែធ្វើសកម្មភាពលួចលើកដំបូងតែប៉ុណ្ណោះ ហើយខ្លួនមិនធ្លាប់ប្រើប្រាស់ថ្នាំញៀនពីមុនមកទេ ចំពោះអំពើឆក់ទូរស័ព្ទដៃនេះផងដែរ គឺឈ្មោះ [redacted] ចំណាត់ ជាអ្នកបបួលខ្លួន និងបង្គាប់ឱ្យខ្លួនធ្វើសកម្មភាពនេះ ។

-ជនជាប់ចោទឈ្មោះ [redacted] ចំណាត់ បានឆ្លើយថា៖ ខ្លួនចេញឆក់ជាមួយឈ្មោះ [redacted] ដេវីត បានម្តង ។ ខ្លួនឆក់បានពីរលើកហើយ។ ខ្លួនពុំមានមុខរបរ នោះទេ ហើយម្តាយរបស់ខ្លួនលកនំ។ ខ្លួនឃើញគេមានលុយចង់មានដូចគេ ។ ខ្លួនបានស្គាល់ពីរនាក់ទៀតឈ្មោះ [redacted] សុវណ្ណារ៉ាវី និង ឈ្មោះ [redacted] វាសនា ដោយសាររៀនជាមួយគ្នា តែពីរនាក់ទៀត ពុំបានឆក់ជាមួយខ្លួនទេ។

-ជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស បានឆ្លើយថា៖ ពេលធ្វើសកម្មភាពឆក់ទូរស័ព្ទជាមួយឈ្មោះ[redacted]សុវណ្ណារ៉ាវី ដោយពេលនោះខ្លួនជាអ្នកឌុបឈ្មោះ [redacted] សុវណ្ណារ៉ាវី ហើយឈ្មោះ សុ វណ្ណារ៉ាវី ជាអ្នកធ្វើសកម្មភាពឆក់ ។ ខ្លួនបានធ្វើសកម្មភាពឆក់នៅម្តុំអង្គស្នួល ដោយពេលនោះខ្លួនបានធ្វើសកម្មភាបឆក់ទូរស័ព្ទរបស់ជនរងគ្រោះ ភេទស្រី ដែលជិះម៉ូតូម៉ាក TODAY ។ ចំពោះម៉ូតូរបស់ខ្លួន និងម៉ូតូជនរងគ្រោះជិះស្របទិសជាមួយគ្នា រួចខ្លួនក៏ជិះម៉ូតូពីក្រោយជនរងគ្រោះ ហើយឈ្មោះ[redacted] សុវណ្ណារ៉ាវី ក៏បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃនោះតែម្តង ។ ពេលធ្វើសកម្មភាពឆក់នោះ ខ្លួនធ្វើសកម្មភាពឆក់បានសម្រេចបាននូវទូរស័ព្ទម៉ាក IPHONE XS MAX ពណ៌ទឹកមាស ហើយខ្លួនក៏បានយកទូរស័ព្ទនោះទៅលក់នៅម្តុំផ្សារកំបូល (បុរីពិភពថ្មី) ដោយពេលនោះខ្លួនលក់បាន២៥០$ (ពីររយហាសិបដុល្លាអាមេរិក) ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនចំនួន៦ខែមកហើយ ដែលខ្លួនបានទិញនៅម្តុំផ្លូវវេងស្រេងដោយមិនស្គាល់ឈ្មោះឡើយ ដោយទិញក្នុងតម្លៃ៣០.០០០រៀល(បីម៉ឺនរៀល) ក្នុងមួយកញ្ចប់ ។ពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួន គឺបានដកហូតនូវម៉ូតូ ០១គ្រឿង ម៉ាក HONDA C125 ស៊េរីឆ្នាំ 2018 ពណ៌ខ្មៅ ដែលមានស្លាកលេខ 1AA-3001 ដែលជារបស់ឪពុកខ្លួន ទូរស័ព្ទ០១ គ្រឿងម៉ាក IPHONE 11PRO MAX ០១គ្រឿង និងចញ្ចៀនផ្លាកទីន០១វង់ ។

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ាវី ភេទប្រុស បានឆ្លើយថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០២២ វេលាម៉ោង ៦ល្ងាច នៅម្តុំអង្គស្នួល ខ្លួនក៏បានជិះម៉ូតូម៉ាក HONDA DREAM C125 ស៊េរីឆ្នាំ២០១៨ ឡើងតែម២០២១ ពេលនោះខ្លួនក៏បានទីម៉ាតតេលា ដើម្បីជួបសង្សាហើយពេលនោះចាំយូពេក ខ្លួនក៏បានបកត្រឡប់ទៅផ្ទះវិញ។ ពេលដែលបកត្រឡប់ទៅផ្ទះវិញ ខ្លួនក៏បានឃើញជនរងគ្រោះបានដាក់ទូរស័ព្ទនៅពីខាងក្រោយហោប៉ៅខោ ឃើញដូចនេះខ្លួនក៏បានជិះពីក្រោយជនរងគ្រោះ រហូតដល់កន្លែងងស្ងាត់ទើបខ្លួនបានធ្វើសកម្មភាពឆក់យកទូរស័ព្ទរបស់ជនរងគ្រោះ។ ដោយពេលនោះខ្លួនក៏ឆក់បានសម្រេច ដោយឆក់បានទូរស័ព្ទម៉ាក IPHONE XS. ពណ៌មាស ហើយពេលឆក់ខ្លួនបានយកទូរស័ព្ទទៅលក់នៅម្តុំផ្សាកំបូល ក្នុងតម្លៃ ២២០$ (ពីររយម្ភៃដុល្លាអាមេរិក) ។ ខ្លួនបានយកលុយនោះទៅចាយជាមួយឈ្មោះ មាន វាសនា ដោយចែកគ្នាស្មើរ ម្នាក់ចំនួន ១១០$ (មួយរយដប់ដុល្លាអាមេរិក) មូលហេតុដែលខ្លួនចែកប្រាក់ឱ្យឈ្មោះ មាន វាសនា ដោយសារតែគាត់ជាម្ចាស់ម៉ូតូ និងបានឌុបខ្លួនធ្វើសកម្មភាពលួចនោះ។ ខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០៨(ប្រាំបី)ដង មកហើយ ។ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន២ទៅ៣ខែមកហើយ ។ពេលសមត្ថកិច្ចឃាត់ គឺបានដកហូតទូរស័ព្ទរបស់ខ្លួនទេចំនួន០១(មួយ)គ្រឿង ម៉ាកIPHONE XS ពណ៌មាស និងលុយចំនួន៣០០.០០០(បីសែន)រៀល ។

-អានចម្លើយដើមបណ្តឹងឈ្មោះ [redacted] អាលីហ្សា ថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៤ និង៣០នាទី ខ្លួននិងមិត្តភក្តិស្រីប្រាំមួយនាក់ទៀតទាំងអស់ប្រាំពីរនាក់ជិះម៉ូតូបីគ្រឿងចេញពីត្រពាំងសុក្រម ដើម្បីទៅលេង សួនកំសាន្តអាងហែលទឹកនៅភូមិអង្គស្នួលទី២ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ពេលនោះមិនទាន់ចូលទេ ទៅយកមិត្តភក្តិម្នាក់ទៀតឈ្មោះលីនៅម្តុំវត្តចំបក ឃុំពើក

ហើយទៅដល់ហើយដឹកនាងចេញពីផ្ទះដោយជិះតាមផ្លូវកៅស៊ូវត្តដើម្បីមកអាងហែលទឹកនៅភូមិអង្គស្នួលទី២ វិញដោយម៉ូតូរបស់ខ្លួនជិះគ្នា០៣នាក់ខ្លួនជិះកណ្តាល ស្រាប់តែមានជនសង្ស័យមានគ្នាពីរនាក់ជិះម៉ូតូ០១គ្រឿងម៉ាកឃ្លីកពណ៌ប្រផេះមិនស្គាល់ស្លាកលេខជិះរ៉ាម៉ូតូខ្លួនពីក្រោយ រួចលូកដៃយកទូរស័ព្ទរបស់ខ្លួន០១គ្រឿងម៉ាកIPHONE 7plus ដែលខ្លួនទុកនៅករម៉ូតូ ហើយពេលនោះពួកគេជិះរត់គេចសំដៅទៅផ្លូវជាតិលេខ៤ ពេលនោះពួកខ្លួនស្រែកថាចោរៗ ហើយក៏នាំគ្នាជិះម៉ូតូដេញតាម ហើយពេលនោះមិត្តភក្តិរបស់ខ្លួនបានប្រាប់ថាសមត្ថកិច្ចប៉ុស្តិ៍នគរបាលពើកដេញចាប់ហើយ ពេលនោះខ្លួនក៏បានឈប់ម៉ូតូនៅសាលារៀនអង្គស្នួល បានមួយសន្ទុះក្រោយមកមានមនុស្សស្រីម្នាក់មកប្រាប់ខ្លួនថាមានសមត្ថកិច្ចចាប់បានហើយ ពេលនោះខ្លួនក៏មកកន្លែងសមត្ថកិច្ចប៉ុស្តិ៍នគរបាលពើកដាក់ពាក្យបណ្តឹងតាមនីតិវិធិច្បាប់តែម្តង ។

-អានចម្លើយសាក្សីឈ្មោះ [redacted] រ៉េត ថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៧ និង ១០នាទី រូបខ្លួនទទួលព័ត៌មានពីសមត្ថកិច្ចថាកូនរបស់ខ្លួនឈ្មោះ រ៉េត អាលីហ្សា ត្រូវចោរឆក់ទូរស័ព្ទហើយពេលនោះរូបខ្លួនបានមកដល់កន្លែងសមត្ថកិច្ចនគរបាលស្រុកអង្គស្នួលស្រាប់តែកូនស្រីរបស់ខ្លួនពិតជាត្រូវចោរឆក់ទូរស័ព្ទពិតប្រាកដមែន។

-អានកំណត់ហេតុ ទទួលវត្ថុតាង មានវត្ថុតាងឧបករណ៍ប្រើប្រាស់គ្រឿងញៀន (ដប់ទឹកសុទ្ធមានទុយោទឹកកៃច្នៃជក់គ្រឿងញៀន)។

-អានកំណត់ហេតុទទួលស្គាល់វត្ថុតាង នៅអធិការដ្ឋាននគរបាលស្រុកអង្គស្នួល មានឧបករណ៍ប្រើប្រាស់គ្រឿងញៀន (ដប់ទឹកសុទ្ធមានទុយោទឹកកៃច្នៃជក់គ្រឿងញៀន) ,ទូរស័ព្ទដៃចំនួនពីរគ្រឿងម៉ាក IPHONE XS MAX មួយគ្រឿង និងម៉ាក IPHONE 11PRO មួយគ្រឿង និង ម៉ូតូមួយគ្រឿងម៉ាកសង់125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៨ ឡើងតែម២០២២ ស្លាកលេខ 1AA-3100 បានដកហូតពីឈ្មោះ [redacted] វាសនា និង ឈ្មោះ [redacted] សុវណ្ណារ៉ាវី។

-អានកំណត់ហេតុទទួលវត្ថុតាង នៅអធិការដ្ឋាននគរបាលស្រុកអង្គស្នួល មាន ម៉ូតូមួយគ្រឿងម៉ាកឃ្លីចពណ៌ប្រផេះសេរីឆ្នាំ ២០២១ ស្លាកលេខ ភ្នំពេញ 1IJ-7881បានដកហូតពីឈ្មោះ [redacted] ដេវីត ។

-អានពាក្យស្នើសុំម៉ូតូ របស់ឈ្មោះ [redacted] សោភា ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២ បានស្នើសុំម៉ូតូមួយគ្រឿងម៉ាកសង់125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៨ ឡើងតែម២០២២ ស្លាកលេខ 1AA-3100 ជាកម្មសិទ្ធិរបស់ខ្លួន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណី តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយសាក្សី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានា ឃើញថាជនជាប់ឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] វាសនា,ឈ្មោះ [redacted] សុវណ្ណារ៉ា ពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទប្រាកដមែន ដែលច្បាប់កំណត់ថាជាបទលួចមានស្ថានទម្ងន់ទោស ដោយការប្រើប្រាស់ហិង្សា និងប្រើប្រាស់ដោយល្មើសនូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ស្ថិតនៅ ភូមិចំការគ្រោច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដេវីត និង ឈ្មោះ [redacted] វាសនា សន្និដ្ឋាន៖ កូនក្តីរបស់ខ្លួនជាអនីតិជន បានឆ្លើយសារភាពនូវទង្វើរបស់ខ្លួន ដូចនេះស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចសម្រាលទោស ដោយផ្អែកតាមមាត្រា ៩៣ , ៩៤ និង មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

# យល់ឃើញថា

## ក/ អំពីពិរុទ្ធភាព

១-តាមដីកាដំណោះស្រាយលេខ ៨៨៧ ដកដស ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] ចំណាត់ (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាលបញ្ជូនមកជំនុំជម្រះពីបទ: លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការត្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ហើយឈ្មោះ [redacted]វាសនា ,ឈ្មោះ [redacted]សុវណ្ណរ៉ាវី (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាលបញ្ជូនមកជំនុំជម្រះពីបទ: លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការត្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ជនជាប់ចោទឈ្មោះ [redacted] ដេវីត ឆ្លើយថា៖ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ប្រហែលពេលថ្ងៃត្រង់ ដោយពេលនោះខ្លួនបានជិះម៉ូតូ០២នាក់ ជាមួយឈ្មោះ [redacted] ចំណាត់ ដែលឈ្មោះ [redacted] ចំណាត់ជាអ្នកឌុបខ្លួន ហើយខ្លួនជិះម៉ូតូពីក្រោយ។ ដោយពេលនោះខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះដោយពេលនោះជនរងគ្រោះទុកទូរស័ព្ទនៅក្នុងឃ្លុបម៉ូតូ ហើយម៉ូតូរបស់ខ្លួន និងម៉ូតូរបស់ជនរងគ្រោះ គឺជិះស្របទិសជាមួយគ្នា។ ដោយពេលនោះ ខ្លួនបានធ្វើសកម្មភាពលួចបានសម្រេច បាននូវទូរស័ព្ទIPHONE 7 ពណ៌ខ្មៅ០១គ្រឿង ខ្លួនទើបតែធ្វើសកម្មភាពលួចលើកដំបូងតែប៉ុណ្ណោះ ហើយខ្លួនមិនធ្លាប់ប្រើប្រាស់ថ្នាំញៀនពីមុនមកទេ ចំពោះអំពើឆក់ទូរស័ព្ទដៃនេះផងដែរ គឺឈ្មោះ [redacted]ចំណាត់ ជាអ្នកបបួលខ្លួន និងបង្គាប់ឱ្យខ្លួនធ្វើសកម្មភាពនេះ ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ចំណាត់ ឱ្យដឹងថា៖ ខ្លួនចេញឆក់ជាមួយឈ្មោះ [redacted] ដេវីត បានម្តង ។ ខ្លួនឆក់បានពីរលើកហើយ។ ខ្លួនពុំមានមុខរបរ នោះទេ ហើយម្តាយរបស់ខ្លួនលក់នំ។ ខ្លួនឃើញគេមាន លុយចង់មានដូចគេ ។ ខ្លួនបានស្គាល់ពីរនាក់ទៀតឈ្មោះ [redacted]សុវណ្ណរ៉ាវី និង ឈ្មោះ [redacted] វាសនា ដោយសាររៀនជាមួយគ្នា តែពីរនាក់ទៀត ពុំបានឆក់ជាមួយខ្លួនទេ។

៤-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស ឱ្យដឹងថា៖ ពេលធ្វើសកម្មភាពឆក់ទូរស័ព្ទ ជាមួយឈ្មោះ [redacted] សុវណ្ណរ៉ាវី ដោយពេលនោះខ្លួនជាអ្នកឌុបឈ្មោះ [redacted] សុវណ្ណរ៉ាវី ហើយឈ្មោះ [redacted]វណ្ណរ៉ាវី ជាអ្នកធ្វើសកម្មភាពឆក់ ។ ខ្លួនបានធ្វើសកម្មភាពឆក់នៅម្តុំអង្គស្នួល ដោយពេលនោះខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះ ភេទស្រី ដែលជិះម៉ូតូម៉ាក TODAY ។ ចំពោះម៉ូតូរបស់ខ្លួន និងម៉ូតូជនរងគ្រោះជិះស្របទិសជាមួយគ្នា រួចខ្លួនក៏ជិះម៉ូតូពីក្រោយជនរងគ្រោះ ហើយឈ្មោះ [redacted]សុវណ្ណរ៉ាវី ក៏បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃនោះតែម្តង ។ ពេលធ្វើសកម្មភាពឆក់នោះ ខ្លួនធ្វើសកម្មភាពឆក់បានសម្រេចបាននូវទូរស័ព្ទម៉ាក IPHONE XS MAX ពណ៌ទឹកមាស ហើយខ្លួនក៏បានយកទូរស័ព្ទនោះទៅលក់នៅម្តុំផ្សារកំបូល (បុរីពិភពថ្មី) ដោយពេលនោះខ្លួនលក់បាន២៥០$ (ពីររយហាសិបដុល្លាអាមេរិក)។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនចំនួន៦ខែមកហើយ ដែលខ្លួនបានទិញនៅម្តុំផ្លូវវេងស្រេងដោយមិនស្គាល់ឈ្មោះឡើយ ដោយទិញក្នុងតម្លៃ៣០.០០០រៀល(បីម៉ឺនរៀល) ក្នុងមួយកញ្ចប់។ ពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួន គឺបានដកហូតនូវម៉ូតូ ០១គ្រឿង ម៉ាក HONDA C125 ស៊េរីឆ្នាំ 2018 ពណ៌ខ្មៅ ដែលមានស្លាកលេខ 1AA-3001 ដែលជារបស់ឪពុកខ្លួន ទូរស័ព្ទ០១ គ្រឿងម៉ាក IPHONE 11PRO MAX ០១គ្រឿង និងចញ្ចៀនផ្លាកទីន០១វង់ ។



Scanned with CamScanner

៥-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ាវី ភេទប្រុស ឱ្យដឹងថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៦ល្ងាច នៅម្តុំអង្គស្នួល ខ្លួនក៏បានជិះម៉ូតូម៉ាក HONDA DREAM C125 ស៊េរីឆ្នាំ២០១៨ ឡើងតែម២០២១ ពេលនោះខ្លួនក៏បានទិញម៉ាតតេលា ដើម្បីជួបសង្សាហើយពេលនោះចាំឃ្លាពេក ខ្លួនក៏បានបកត្រឡប់ទៅផ្ទះវិញ។ ពេលដែលបកត្រឡប់ទៅផ្ទះវិញ ខ្លួនក៏បានឃើញជនរងគ្រោះបានដាក់ទូរស័ព្ទនៅពីខាងក្រោយហោប៉ៅខោ ឃើញដូចនេះខ្លួនក៏បានជិះពីក្រោយជនរងគ្រោះរហូតដល់កន្លែងងងស្ងាត់ទើបខ្លួនបានធ្វើសកម្មភាពឆក់យកទូរស័ព្ទរបស់ជនរងគ្រោះ។ ដោយពេលនោះខ្លួនក៏ឆក់បានសម្រេច ដោយឆក់បានទូរស័ព្ទម៉ាក IPHONE XS ពណ៌មាស ហើយពេលឆក់ខ្លួនបានយកទូរស័ព្ទទៅលក់នៅម្តុំផ្សារកំបូល ក្នុងតម្លៃ ២២០$ (ពីររយម្ភៃដុល្លាអាមេរិក) ។ ខ្លួនបានយកលុយនោះទៅចាយជាមួយឈ្មោះ មាន វាសនា ដោយចែកគ្នាស្មើរ ម្នាក់ចំនួន ១១០$ (មួយរយដប់ដុល្លាអាមេរិក) មូលហេតុដែលខ្លួនចែកប្រាក់ឱ្យឈ្មោះ [redacted] វាសនា ដោយសារតែគាត់ជាម្ចាស់ម៉ូតូ និងបានឌុបខ្លួនធ្វើសកម្មភាពលួចនោះ។ ខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០៨(ប្រាំបី)ដង មកហើយ ។ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន២ទៅ៣ខែមកហើយ ។ពេលសមត្ថកិច្ចឃាត់ គឺបានដកហូតទូរស័ព្ទរបស់ខ្លួនទេចំនួន០១(មួយ)គ្រឿង ម៉ាកIPHONE XS ពណ៌មាស និងលុយចំនួន៣០០.០០០(បីសែន)រៀល ។

៦-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] អាលីហ្សា ឱ្យដឹងថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៤ និង៣០នាទី ខ្លួននិងមិត្តភក្តិស្រីប្រាំមួយនាក់ទៀតទាំងអស់ប្រាំពីរនាក់ជិះម៉ូតូបីគ្រឿង ចេញពីគ្រពាំងសុក្រម ដើម្បីទៅលេង សួនកំសាន្តអាងហែលទឹកនៅភូមិអង្គស្នួលទី២ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ពេលនោះមិនទាន់ចូលទេ ទៅយកមិត្តភក្តិម្នាក់ទៀតឈ្មោះលីនៅម្តុំវត្តចំបក ឃុំពើក ហើយទៅដល់ហើយដឹកនាងចេញពីផ្ទះដោយជិះតាមផ្លូវកៅស៊ូវត្តដើម្បីមកអាងហែលទឹកនៅភូមិអង្គស្នួលទី២ វិញដោយម៉ូតូរបស់ខ្លួនជិះគ្នា០៣នាក់ខ្លួនជិះកណ្តាល ស្រាប់តែមានជនសង្ស័យមានគ្នាពីរនាក់ជិះម៉ូតូ០១គ្រឿងម៉ាកឃ្លីកពណ៌ប្រផេះមិនស្គាល់ស្លាកលេខជិះរ៉ាម៉ូតូខ្លួនពីក្រោយ រួចលូកដៃយកទូរស័ព្ទរបស់ខ្លួន០១គ្រឿងម៉ាកIPHONE 7plus ដែលខ្លួនទុកនៅករម៉ូតូ ហើយពេលនោះពួកគេជិះរត់គេចសំដៅទៅផ្លូវជាតិលេខ៤ ពេលនោះពួកខ្លួនស្រែកថាចោរ ហើយក៏នាំគ្នាជិះម៉ូតូដេញតាម ហើយពេលនោះមិត្តភក្តិរបស់ខ្លួនបានប្រាប់ថាសមត្ថកិច្ចប៉ុស្តិ៍នគរបាលពើកដេញចាប់ហើយ ពេលនោះខ្លួនក៏បានឈប់ម៉ូតូនៅសាលារៀនអង្គស្នួល បានមួយសន្ទុះក្រោយមកមានមនុស្សស្រីម្នាក់មកប្រាប់ខ្លួនថាមានសមត្ថកិច្ចចាប់បានហើយ ពេលនោះខ្លួនក៏មកកន្លែងសមត្ថកិច្ចប៉ុស្តិ៍នគរបាលពើកដាក់ពាក្យបណ្តឹងតាមនីតិវិធិច្បាប់តែម្តង ។

៧-តាមចម្លើយសាក្សីឈ្មោះ [redacted] រ៉េត ឱ្យដឹងថា៖ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១៧ និង ១០នាទី រូបខ្លួនទទួលព័ត៌មានពីសមត្ថកិច្ចថាកូនរបស់ខ្លួនឈ្មោះ [redacted] អាលីហ្សា ត្រូវចោរឆក់ទូរស័ព្ទហើយពេលនោះរូបខ្លួនបានមកដល់កន្លែងសមត្ថកិច្ចនគរបាលស្រុកអង្គស្នួល ស្រាប់តែកូនស្រីរបស់ខ្លួនពិតជាត្រូវចោរឆក់ទូរស័ព្ទពិតប្រាកដមែន។

៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណី តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយសាក្សីនិងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានា ឃើញថាជនជាប់ឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] វាសនា,ឈ្មោះ [redacted] សុវណ្ណារ៉ាវី ពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទប្រាកដមែន ដែលច្បាប់កំណត់ថាជាបទលួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា និងប្រើប្រាស់ដោយច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ស្ថិតនៅភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

៩-មេធាវីការពារសិទ្ធិឱ្យជនចាប់ចោទឈ្មោះ [redacted] ដេវីត និង ឈ្មោះ មាន វាសនា សន្និដ្ឋានៈ កូនក្តីរបស់ខ្លួនជាអនីតិជន បានឆ្លើយសារភាពនូវទង្វើរបស់ខ្លួន ដូចនេះស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចសម្រាលទោសដោយផ្អែកតាមមាត្រា ៩៣ មាត្រា ៩៤ និង មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ។

១០-តាមរបាយការណ៍សរុបលេខ ០០៦/២២ រ.ប.ក របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល បានសន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] ដេវីត ភេទប្រុស អាយុ១៧ឆ្នាំ ,ឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] វាសនា ភេទប្រុស ១៧ឆ្នាំ ,ឈ្មោះ [redacted] សុវណ្ណារ៉ាវី ភេទប្រុស អាយុ១៩ឆ្នាំ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះឈ្មោះ [redacted] អាលីហ្វា ប្រាកដមែន ។

១១.ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ទាំង៤នាក់ និង ចម្លើយជនរងគ្រោះ ព្រមទាំងរបាយការណ៍របស់មន្ត្រីនគរបាល បានអោយដឹងថា ជនជាប់ចោទឈ្មោះ [redacted] ចំណាត់ និង ជនជាប់ចោទឈ្មោះ [redacted] ដេវី បានជិះម៉ូតូមួយគ្រឿង ដែលឈ្មោះ [redacted] ចំណាត់ជាអ្នកបើកម៉ូតូ បានលួចដកហូតយកទូរស័ព្ទដៃពីក្នុងគ្លបម៉ូតូ របស់ជនរងគ្រោះឈ្មោះ [redacted] អាលីហ្វា ដែលកំពុងធ្វើដំណើរតាមផ្លូវ។ ក្នុងករណីនេះ សមត្ថកិច្ចចាប់បានជនជាប់ចោទទាំងពីរនេះ រួចបានបន្តឃាត់ខ្លួនឈ្មោះ រស់ សុវណ្ណារ៉ាវី និង [redacted] វាសនា ទៀតដែលជាក្រុមជាមួយគ្នា ដោយជនជាប់ចោទទាំងពីរនេះ ដែលបានធ្វើសកម្មភាពជាមួយគ្នា លួចយកទូរស័ព្ទរបស់ជនរងគ្រោះពីក្នុងហោប៉ៅខោ។ អំពើរបស់ជនជាប់ចោទទាំង៤នាក់នេះជា អំពើដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយពុំមានប្រើអំពើហិង្សានោះទេ គប្បីតុលាការកែប្រែបទចោទ ពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ទៅជាបទអំពើលួច តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការក្រោច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២។

១២.ជនជាប់ចោទឈ្មោះ [redacted] ដេវីត ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ១៧ឆ្នាំ ជាអនីតិជន បានឆ្លើយសារភាព និង ទទួលស្គាល់កំហុស គប្បីទទួលបាននូវការសម្រាលទោស ផ្អែកតាមបញ្ញត្តិមាត្រា ៩៣,៩៤,និងមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ។

១៣-ជនជាប់ចោទ ឈ្មោះ [redacted] សុវណ្ណារ៉ាវី ហៅហ្វា ហៅហុង ភេទប្រុស អាយុ១៩ឆ្នាំ,ឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ភេទប្រុស អាយុ ២១ឆ្នាំ ជានីតិជនមានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

១៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] ចំណាត់ ដែលបានប្រព្រឹត្តបានធ្វើឱ្យប៉ះពាល់សន្តិសុខសណ្តាប់ធ្នាប់សង្គមរបៀបរៀបរយសង្គមជាបទ អំពើលួច ដែលជាអំពើបំពានច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និង ឈ្មោះ [redacted] វាសនា និង ឈ្មោះ [redacted] សុវណ្ណារ៉ាវី ពីបទ អំពើលួច និង បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥-មានធាតុផ្សំជាបទល្មើសព្រហ្មទណ្ឌដែលមានចែងច្បាស់លាស់ឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៦-មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] ដេវីត, ឈ្មោះ [redacted] ចំណាត់ ពីបទ អំពើលួច និង ឈ្មោះ [redacted] វាសនា និង ឈ្មោះ [redacted] សុវណ្ណារ៉ាវី ពីបទ អំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

១៧.ឈ្មោះ [redacted] សោភា ជាម្ដាយរបស់ជនជាប់ចោទ ឈ្មោះ [redacted] វាសនា បានស្នើសុំម៉ូតូមួយគ្រឿងម៉ាកសង់125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៨ ឡើង តែម២០២២ ស្លាកលេខ 1AA-3100 ជាកម្មសិទ្ធិរបស់ខ្លួន ដើម្បីយកទៅប្រើប្រាស់វិញ គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមដើម្បីយកទៅប្រើប្រាស់ ក្នុងជីវភាពវិញ ។

**ខ/ អំពីវត្ថុតាង**

១-ឧបករណ៍ប្រើប្រាស់គ្រឿងញៀន (ដប់ទឹកសុទ្ធមានទុយោទឹកកៃច្នៃជក់គ្រឿងញៀន)។

ម៉ូតូមួយគ្រឿងម៉ាកឃ្លីច ពណ៌ប្រផេះ សេរីឆ្នាំ ២០២១ ស្លាកលេខ ភ្នំពេញ 1IJ-7881 គប្បីតុលាការរឹបអូស។

២-ទូរស័ព្ទដៃចំនួនពីរគ្រឿងម៉ាក IPHONE XS MAX មួយគ្រឿង និងម៉ាក IPHONE 11PRO មួយគ្រឿង និង ម៉ូតូមួយគ្រឿងម៉ាកសង់125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៨ ឡើងតែម២០២២ ស្លាកលេខ 1AA-3100 គប្បីតុលាការសម្រេចប្រគល់ទៅម្ចាស់ដើមតាមការស្នើសុំ។

**ហេតុដូច្នេះសម្រេច**

១-កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] ដេវី ,ឈ្មោះ [redacted] វាសនា ,ឈ្មោះ [redacted] សុវណ្ណារ៉ាវី និងឈ្មោះ [redacted] ចំណាត់ ពីបទលួចមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់ហិង្សា តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ អំពើលួច តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្លូវបេតុង ភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២។

២-ផ្ដន្ទាទោសលើជនជាប់ចោទ

២.១.ឈ្មោះ [redacted] ដេវីត (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ ៣ (បី) ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ៧ (ប្រាំពីរ) ខែ ទោសនៅសល់ត្រូវព្យួរ

២.២.ឈ្មោះ [redacted] ចំណាត់ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ រយៈពេល ២ (ពីរ)ឆ្នាំ ៦ (ប្រាំមួយ) ខែ

ពីបទ:អំពើលួច ប្រព្រឹត្តនៅលើផ្លូវបេតុង ភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២.៣.ឈ្មោះ [redacted] វាសនា (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ ៣ (បី) ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ៧ (ប្រាំពីរ) ខែ ទោសនៅសល់ត្រូវព្យួរ

២.៤.ឈ្មោះ [redacted] សុវណ្ណារ៉ាវី (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ ២ (ពីរ)ឆ្នាំ ៦ (ប្រាំមួយ) ខែ

ពីបទ:អំពើលួច និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅលើផ្លូវបេតុង ភូមិចំការគ្រាច ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-វត្ថុចាប់យក

៣.១.ឧបករណ៍ប្រើប្រាស់គ្រឿងញៀន (ដប់ទឹកសុទ្ធមានទុយោទឹកកៃច្នៃជក់គ្រឿងញៀន) ត្រូវរឹបអូសបំផ្លាញចោល ។

៣.២.ម៉ូតូមួយគ្រឿងម៉ាកឃ្លីច ពណ៌ប្រផេះ សេរីឆ្នាំ ២០២១ ស្លាកលេខ ភ្នំពេញ 1IJ-7881 ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

៣.៤.ម៉ូតូមួយគ្រឿងម៉ាកសង់125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៨ ឡើងតែម២០២២ ស្លាកលេខ 1AA-3100 ប្រគល់អោយម្ចាស់ដើមឈ្មោះ [redacted] សោភា ។



Scanned with CamScanner

៣.៥.ទូរស័ព្ទដៃចំនួនពីរគ្រឿងម៉ាក IPHONE XS MAX មួយគ្រឿង និងម៉ាក IPHONE 11PRO មួយគ្រឿងត្រូវប្រគល់អោយម្ចាស់ដើមវិញ ។

៤.ចេញដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ [redacted] ចំណាត់ ផ្អែកតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមជំនុំជម្រះ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២២ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដេវីត ,ឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] វាសនា,ឈ្មោះ [redacted] សុវណ្ណារ៉ាវី តែកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អាលីហ្សា ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| [redacted] | [redacted] | [redacted] | |

បានឃើញ

ថ្ងៃ.......................២០២២

តំណាងអយ្យការ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្ដាល,ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner